# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ០៧៥/២០ ក.ប/ស.ជ.ណ.ម.ហ

## សេចក្តីជូនដំណឹង
## ស្តីពី
## ការផ្លាស់ប្តូរកាលបរិច្ឆេទធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន សម្រាប់ពលករជំនាញផ្នែកថែទាំ ដើម្បីទៅធ្វើការនៅប្រទេសជប៉ុន

យោងតាមការជូនដំណឹងរបស់ក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជន ដែលមានបំណងទៅធ្វើការនៅប្រទេសជប៉ុន ក្នុងគម្រោងពលករជំនាញ ឱ្យបានជ្រាបថា កាលបរិច្ឆេទនៃការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន សម្រាប់គម្រោងពលករជំនាញផ្នែកថែទាំ ដែលបានគ្រោងរៀបចំធ្វើឡើង ចាប់ពីថ្ងៃទី១៧-១៩ ខែសីហា ឆ្នាំ២០២០ តាមរយៈសេចក្តីជូនដំណឹងលេខ ០២១/២០ ក.ប/ ស.ជ.ណ.ម.ហ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ **ត្រូវបានផ្លាស់ប្តូរ** ទៅរៀបចំនៅក្នុងខែតុលា ឆ្នាំ២០២០ ខាងមុខវិញ។ កាលបរិច្ឆេទថ្មី នៃការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន សម្រាប់គម្រោងពលករជំនាញផ្នែកថែទាំ ក្នុងខែតុលា នឹងប្រព្រឹត្តទៅចំនួន ២លើក ដូចខាងក្រោម៖

- កាលបរិច្ឆេទប្រឡង ៖ នៅថ្ងៃទី១៣-១៤ ខែតុលា ឆ្នាំ២០២០
  - មណ្ឌលមណ្ឌលសកលវិទ្យាល័យអន្តរជាតិ ប៊ែលធី (សាខាទួលស្លែង)
  - អាសយដ្ឋាន ៖ ផ្ទះលេខ២១ ផ្លូវលេខ៣៦០ សង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
- កាលបរិច្ឆេទប្រឡង ៖ នៅថ្ងៃទី២៣-២៤ ខែតុលា ឆ្នាំ២០២០
  - មណ្ឌលវិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំ (EDI)
  - អាសយដ្ឋាន ៖ ផ្ទះលេខ៩A ផ្លូវលេខ៣៧០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

ក្នុងករណីមានការប្រែប្រួលណាមួយ ក្រសួងនឹងជូនដំណឹងបន្ថែមទៀត។

សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងលេខទូរស័ព្ទ +603 76283371 (ប្រទេសជប៉ុន) រៀងរាល់ម៉ោងធ្វើការ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជន ដែលមានបំណងចង់សុំចុះឈ្មោះធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន ជ្រាបតាមការគួរ។

ថ្ងៃ ពុធ ៨រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន**

- -សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា(ACRA)
- -សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា(MAC)
- -ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់
  "ដើម្បីជួយផ្សព្វផ្សាយ និងសហការ"
- -ឯកសារ-កាលប្បវត្តិ